# ករណីសិក្សាៈ អត្ថប្រយោជន៍ប្រព័ន្ធជំនួយសង្គម




អង្គុយនៅក្រោមផ្ទះមានទឹកមុខស្រងូតស្រងាត់ លោកយាយ រេម កុយ មានវ័យ ៧០ ឆ្នាំ និងជាជនជាតិដើមភាគតិចក្លួយ ហើយជាស្ត្រីមេម៉ាយកូនមួយផងនោះ សព្វថ្ងៃលោកយាយរស់ក្នុងសហគមន៍ដាច់ស្រយាលមួយនៃ ខេត្តព្រះវិហារ។

លោកយាយមានកូនប្រុសម្នាក់អាយុ៤២ឆ្នាំ ហើយកូនរបស់លោកយាយបានរៀបការនឹងទៅរស់នៅផ្ទះរបស់ប្រពន្ធគាត់ ដោយទុកឱ្យលោកយាយរស់នៅតែម្នាក់ឯង។

និយាយទាំងទឹកមុខក្រៀមស្រពោន ហាក់មិនសូវមានកម្លាំងកំហែង លោកយាយបានរៀបរាប់អំពីជីវិតប្រចាំថ្ងៃប្រាប់មកអ្នកសម្ភាស៍ថា ពីមុនមកគាត់មានមុខរបរជាអ្នកដើរស៊ីឈ្នួលធ្វើស្រែចំម្ការនៅក្នុងសហគមន៍របស់គាត់ដើម្បីបានប្រាក់កម្រៃខ្លះមកផ្គត់ផ្គង់ជីវភាពរស់នៅប្រចាំថ្ងៃ។ តែដោយសារវ័យកាន់តែចាស់ និងគ្មានកូនចៅពឹងពាក់ផងនោះ លោកយាយបានទៅរស់នៅជាមួយនិងចៅស្រីរបស់គាត់នៅក្នុងភូមិជាមួយគ្នា។

លោកយាយបានបន្តទៀតថាសព្វថ្ងៃនេះស្ថានភាពសេដ្ឋកិច្ចក្នុងសហគមន៍ក៏ដូចជាគ្រួសាររបស់ចៅស្រីក៏មានការធ្លាក់ចុះខ្លាំង រកចំណូលបានតិច តែចំណាយច្រើនក្នុងជីវភាពប្រចាំថ្ងៃ និងការធ្វើស្រែចំការក៏ទទួលបានទិន្នផលទាបផងដែរ។ លោកយាយមិនអាចជួយចៅស្រីធ្វើការងារអ្វីច្រើនទៀតបានទេ គឺបានត្រឹមជួយមើលចៅម្តងម្កាលពេលខ្លួនបានធូរស្បើយពីជំងឺតែប៉ុណ្ណោះ។

តាមការយល់ឃើញរបស់លោកយាយផ្ទាល់យល់ថា កិច្ចគាំពារសង្គម វាពិតជាបានជួយពួកគាត់ពិតមែន ជាពិសេសស្ត្រីដែលមានផ្ទៃពោះ វាអាចផ្តល់ជូនការពិនិត្យ តាមដានពីសុខភាពរបស់ស្ត្រី មុនពេលសម្រាល និងក្រោយពេលសម្រាលហើយក៏មានការផ្តល់ជាថ្នាំបង្ការដល់ទារកផងដែរ។ ចំណែកមនុស្សចាស់ជរាដូចគាត់ពេលមានជំងឺត្រូវទៅព្យាបាលនៅមន្ទីពេទ្យគឺមិនមានការព្រួយបារម្ភទៅលើការចំណាយនោះទេ។

គាត់បានដឹងថា កិច្ចគាំពារសង្គមបានជួយសម្រាលបន្ទុករូបគាត់ បងប្អូនជនជាតិដើមភាគតិចក្នុងសហគមន៍ របស់គាត់ផងដែរជាពិសេសស្ត្រីក្នុងការពិនិត្យតាមដានសុខភាពពេលពពោះកូនរបស់ពួកគេម្តងៗ និងពេលសម្រាលរួចក៏មានការផ្តល់សេវាចាក់ថ្នាំការពារជំងឺដល់កុមារ និងថ្នាំជំនួយផ្សេងៗផងដែរ។ ម្យ៉ាងទៀតឪពុកម្តាយដែលទទួលបានប័ណ្ណក្រីក្របើឬប័ណ្ណសមធម៌នេះដែលមានកូនអាយុល្មមចូលរៀននោះគេអាចយកប័ណ្ណនេះទៅស្នើរសុំអាហាររូបករណ៍ពីសាលារៀនសម្រាប់ការផ្គត់ផ្គង់ដល់ការសិក្សារៀនសូត្ររបស់កូនបានទៀតផង។

ករណីឈឺតិចតួចពួកគេទៅទទួលការព្យាបាលនៅមណ្ឌលសុខភាពដោយមិនមានតម្រូវឱ្យបង់ប្រាក់ ឬថ្លៃសេវានោះទេ ។ ហើយការទៅទទួលសេវាព្យាបាលពីមណ្ឌលសុខភាពគឺមានភាពងាយស្រួលព្រោះវានៅជិតផ្ទះរបស់គាត់ និងមិនបាច់ចំណាយទៅលើការធ្វើដំណើរ មិនចំណាយពេលវេលាយូរក្នុងការរងចាំនោះទេ។

និយាយទាំងអួលដើមក លោកយាយបានបញ្ជាក់ថា ចំពោះខ្លួនគាត់ផ្ទាល់គាត់ពិតជាចង់ឱ្យរាជរដ្ឋាភិបាលជួយបន្តរសុពលភាពប័ណ្ណសមធម៌នេះជារៀងរហូត ព្រោះគាត់ចាស់ជរាហើយក្នុងគ្រួសារក៏មានសមាជិកច្រើនថែមទៀត។